# ឯកសារអនុសាសន៍ស្តីពីនិរន្តរភាព ក្រោមប្រធានបទ របាយការណ៍ស្តីពីនិរន្តរភាព ក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប

# Enhancing Sustainability Reporting in the GFT Sector in Cambodia

ឯកសារអនុសាសន៍ ស្តីពីនិរន្តរភាព

Sustainability Recommendation Paper




កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

FABRIC Cambodia

RESPONSIBLE BUSINESS HUB CAMBODIA RBH NETWORK

EUROCHAM CAMBODIA

TAFTAC

# សេចក្តីសង្ខេប

ឯកសារអនុសាសន៍ស្តីពីនិរន្តរភាព ក្រោមប្រធានបទ របាយការណ៍ស្តីពីនិរន្តរភាព (Sustainability Reporting) ក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប (GFT) នេះ មានគោលបំណងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តផ្នែកបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ព្រមទាំងការប្រមូលនិងការគ្រប់គ្រងទិន្នន័យសម្រាប់ការរាយការណ៍។ វាពិជាមានសារៈសំខាន់បំផុតដោយសារច្បាប់ថ្មីស្តីពីដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន (HREDD) ដែលភាគច្រើនមកពីប្រទេសលោកខាងជើង (ទីផ្សារអ្នកបញ្ជារទិញ) ទំនោរនឹងបង្កើតអោយមានតម្រូវការអំពីរបាយការណ៍ស្តីពីនិរន្តរភាពនេះ។

សហភាពអឺរ៉ុបគឺជាទីផ្សារគោលដៅដ៏ធំបំផុតមួយរបស់កម្ពុជាសម្រាប់ផលិតផល GFT ដែលមានតម្លៃនាំចេញចំនួន **២.៩ ពាន់លានដុល្លារ** សម្រាប់ការលក់រាយដល់អតិថិជនអឺរ៉ុបនៅឆ្នាំ ២០២៤ ក្រោមប្រព័ន្ធអនុគ្រោះពន្ធអ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ (EBA) លើគ្រប់ប្រភេទផលិតផល (ផលិតផលវាយនភណ្ឌ ស្បែកជើង កង់ គ្រឿងឧបភោគបរិភោគ អង្ករ និងផលិតផលកសិកម្មផ្សេងៗទៀត)។ ដូចនេះ ច្បាប់របស់សហភាពអឺរ៉ុបនាពេលថ្មីៗនេះ ស្តីពីរបាយការណ៍ស្តីពីនិរន្តរភាព និងការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន នឹងមានឥទ្ធិពលយ៉ាងសំខាន់លើវិស័យ GFT និងសមត្ថភាពរបស់វិស័យនេះ ក្នុងការបន្តផ្តល់នូវផលិតផលដែលមានគុណភាព ដែលស្របតាមតម្រូវការរបស់ទីផ្សារសហភាពអឺរ៉ុប។

ខណៈពេលដែលមានការប៉ាន់ប្រមាណថា **៨០**% នៃក្រុមហ៊ុនចំនួន**៥០** ដែលបានចុះបញ្ជីនៅអាស៊ីប៉ាស៊ីហ្វិក បានទទួលយកក្របខណ្ឌ Global Reporting Initiative (GRI) នោះ  ច្បាប់ជាតិដែលមានស្រាប់ និងគោលការណ៍ណែនាំនៅក្នុងប្រទេសកម្ពុជាមិនបានរួមបញ្ចូលរបាយការណ៍ស្តីពីនិរន្តរភាព ឬសូម្បីតែការរាយការណ៍អំពីបរិស្ថាន សង្គម និងអភិបាលកិច្ច ក្រៅពីតម្រូវការមួយចំនួន ដែលបានកំណត់ក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ ឆ្នាំ ២០២៣។ គម្លាតនេះ ផ្តល់នូវបន្ទុកដ៏ធំមួយសម្រាប់ក្រុមហ៊ុននីមួយៗ ក្នុងការអភិវឌ្ឍន៍ និងទិញឧបករណ៍ ប្រព័ន្ធ និងដំណើរការដែលត្រូវការដើម្បីបំពេញតម្រូវការរបស់អ្នកបញ្ជាទិញ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលបណ្តាលឱ្យមានការភ័ន្តច្រឡំ ការចំណាយកើនឡើង និងអាចប្រឈមការបាត់បង់អ្នកបញ្ជារទិញ  ទៅបណ្តាឲ្យប្រទេសផលិត ដែលបានគាំទ្រ និងអនុវត្ត នូវរបាយការណ៍ស្តីពីនិរន្តរភាព ប្រសើរជាងនេះ។

ការសិក្សាដែលពាក់ព័ន្ធនានាឯកភាពថា «ក្នុងចំណោមបញ្ហាជាច្រើនដែលទាក់ទងនឹងនិរន្តរភាព ការប្រែប្រួលអាកាសធាតុ និងធនធានមនុស្ស គឺជាបញ្ហាលេចធ្លោបំផុតនៅអាស៊ី និងទូទាំងពិភពលោក»។ការសិក្សាក៏បង្ហាញផងដែរថា វិនិយោគិនជាច្រើនទំនងជាមានទំនោរទៅលើរបាយការណ៍ ESG ថាជាសញ្ញាសម្គាល់នៃតម្លាភាព និងគណនេយ្យភាព ដែលមានន័យថា ប្រទេសទាំងនោះដែលមានរបាយការណ៍ស្តីពីនិរន្តរភាព ជាទីកន្លែងដែលនឹងផ្តល់នូវការវិនិយោគបានកាន់តែងាយស្រួល និងមានភាពទាក់ទាញ។

សម្រាប់ប្រទេសកម្ពុជា ពួកយើងមិនផ្តល់អនុសាសន៍អោយដាក់បន្ថែមនូវតម្រូវការថ្នាក់ជាតិនានាទៅលើរបាយការណ៍ស្តីពីនិរន្តរភាពឡើយ ដោយសារប្រធានបទនេះស្ថិតនៅក្នុងដំណាក់កាលកំពុងវិវត្តន៍នៅឡើយ។ ច្បាប់ថ្មីអាចបង្កើនភាពស្មុគស្មាញនិងការចំណាយសម្រាប់ក្រុមហ៊ុនដែលផ្តោតលើការនាំចេញនៅក្នុងប្រទេសកម្ពុជា ដែលធ្វើឲ្យក្រុមហ៊ុនទាំងនោះប្រឈមនឹងការបាត់បង់ឧត្តមភាពនៅក្នុងទីផ្សារអន្តរជាតិ។ ផ្ទុយទៅវិញ យើងស្នើឱ្យរដ្ឋាភិបាលបង្កើតជំហានបន្ថែមក្នុងការអភិវឌ្ឍន៍របាយការណ៍ស្តីពីនិរន្តរភាពដើម្បីឆ្ពោះទៅរកស្តង់ដា អន្តរជាតិ។ ជំហានទាំងនេះនឹងគាំទ្រដល់ក្រុមហ៊ុនក្នុងស្រុកក្នុងការបំពេញតម្រូវការសិទ្ធិការងារ និងបរិស្ថានអោយសមស្របតាមតម្រូវការអំពីទិន្នន័យរបស់អ្នកបញ្ជារទិញអន្តរជាតិ។ ដើម្បីឱ្យមានប្រសិទ្ធភាពមូលដ្ឋានគ្រឹះទាំងនេះគួរតែទាញចេញពីច្បាប់អន្តរជាតិដែលបានបង្កើតឡើង និងគោលការណ៍ណែនាំ។

ដើម្បីរក្សាបាននូវវិធីសាស្រ្តជាតិដ៏រឹងមាំមួយក្នុងការគ្រប់គ្រងផលប៉ះពាល់បរិស្ថាន កម្លាំងពលកម្ម និងអាជីវកម្មផ្សេងទៀត កម្ពុជាអាចដាក់ចេញនូវចក្ខុវិស័យដ៏រឹងមាំមួយនៃអាជីវកម្មដែលមានទំនួលខុសត្រូវដែលអនុញ្ញាតឱ្យក្រុមហ៊ុននានា ជាពិសេសក្រុមហ៊ុនដែលនៅក្នុងវិស័យនាំចេញ មានភាពបត់បែនក្នុងការសម្របខ្លួនទៅនឹងរបាយការណ៍ស្តង់ដាអន្តរជាតិ។

ជាឧទាហរណ៍ រាជរដ្ឋាភិបាលកម្ពុជា និងឧស្សាហកម្ម GFT អាចបង្កើតការគាំទ្រផ្នែកច្បាប់សម្រាប់ក្រុមហ៊ុន GFT ដោយជួយពួកគេអនុវត្តស្តង់ដារ HREDD ថ្មី។ ពួកគេក៏អាចបង្កើតក្របខណ្ឌរួមមួយសម្រាប់របាយការណ៍ស្តីពីនិរន្តរភាពដែលស្របតាមក្រុមហ៊ុន GFT របស់កម្ពុជា ដោយយោងទៅលើក្របខណ្ឌពិភពលោកដូចជា UNGPs, OECD Guidelines, ILO Conventions និងស្តង់ដារបរិស្ថាន។ វាអាចដើរតួជាការអនុវត្តន៍ជាក់ស្តែងសម្រាប់រោងចក្រដែលទទួលកុម្ម៉ង់ដោយផ្ទាល់ពីអ្នកបញ្ជារទិញ Tier 1 ដែលនឹង

ត្រូវកំណត់ឱ្យប្រកាន់ខ្ជាប់នូវស្តង់ដារ HREDD និងអាចជាការគាំទ្រដល់រោងចក្រដែលមិនផ្អែកលើការនាំចេញ និងទទួលកុម្ម៉ង់ដោយប្រយោលពីអ្នកបញ្ជារទិញ Tier 2&3 ដើម្បីផ្តួចផ្តើមការអនុវត្តន៍របាយការណ៍ស្តីពីនិរន្តរភាព។ យើងលើកទឹកចិត្តរាជរដ្ឋាភិបាលកម្ពុជាឱ្យចាប់យកឱកាសនេះ។

ទោះបីជាយ៉ាងណាក៏ដោយ **នេះជាឱកាសពិសេសមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងឧស្សាហកម្ម** GFT **ដើម្បីបង្កើតមូលដ្ឋានគ្រឹះរួមសម្រាប់របាយការណ៍ស្តីពីនិរន្តរភាព ដោយផ្អែកលើក្របខ័ណ្ឌនានាដូចជា គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ**(UNGPs) **គោលការណ៍ណែនាំនានារបស់** OECD **អនុសញ្ញា** ILO **និងស្តង់ដារបរិស្ថាននានា។ យើងសូមណែនាំឲ្យរាជរដ្ឋាភិបាលចាប់យកឱកាសនេះ។**

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស (UNGPs) និង ការណែនាំស្តីពីការអនុវត្តកាតព្វកិច្ចតាមច្បាប់របស់អង្គការ OECD សម្រាប់ខ្សែចង្វាក់ផ្គត់ផ្គង់ដែលមានទំនួលខុសត្រូវ ក្នុងវិស័យកាត់ដេរ និងស្បែកជើង (OECD Guidelines) ត្រូវបានបង្កើតឡើង និងទទួលយកបានយ៉ាងល្អ ជាមូលដ្ឋានគ្រឹះនៃច្បាប់ថ្មីៗជាច្រើនស្តីពីសិទ្ធិមនុស្សនិង ដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវផ្អែកសិទ្ធិមនុស្ស និងបរិស្ថាន (HREDD)។

ទាំងនេះអាចសម្រេចបានដោយការផ្តល់នូវឧបករណ៍សម្រាប់ការវាស់វែងទិន្នន័យ ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីជួយដល់ក្រុមហ៊ុនក្នុងការទទួលយកការអនុវត្តប្រកបដោយនិរន្តរភាព និងការកែលម្អប្រព័ន្ធគ្រប់គ្រង ជាពិសេសសម្រាប់ការតាមដានផលប៉ះពាល់បរិស្ថាន និងសង្គម។ វឌ្ឍនភាពនៃរបាយការណ៍ស្តីពីនិរន្តរភាព **នឹងនាំទៅរកប្រតិបត្តិការកាន់តែប្រសើរឡើង** ការពង្រឹងលទ្ធផលបរិស្ថាន និងសង្គម និងការបង្កើនភាពប្រកួតប្រជែងសម្រាប់ធុរកិច្ចនៅកម្ពុជា ជាពិសេសជាមួយអតិថិជននៅសហភាពអឺរ៉ុប ដែលអាចផ្តល់តម្លៃខ្ពស់សម្រាប់ទិន្នន័យនិរន្តរភាពដែលអាចជឿទុកចិត្តបាន។ ភាពដឹកនាំរបស់រាជរដ្ឋាភិបាល នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការ ផ្សាភ្ជាប់ជាមួយភាគីពាក់ព័ន្ធ ដើម្បីជំរុញការផ្លាស់ប្តូរនេះ។

## បញ្ហាប្រឈមសំខាន់ៗ

អត្ថបទនេះបង្ហាញពីបញ្ហាប្រឈមសំខាន់ៗទាក់ទងនឹងរបាយការណ៍ស្តីពីនិរន្តរភាពនៅក្នុងវិស័យ GFT របស់កម្ពុជា៖

១. **ការយល់ដឹងនៅមានកម្រិត** អំពីគោលការណ៍និរន្តរភាព រួមទាំងការគ្រប់គ្រងទិន្នន័យ និងតម្លាភាព។
២. **ប្រព័ន្ធគ្រប់គ្រងនិងប្រមូលទិន្នន័យ**នៅក្នុងរោងចក្រ នៅមានកម្រិត។
៣. **កង្វះឧបករណ៍**ដែលមានលក្ខណៈងាយស្រួលប្រើប្រាស់សម្រាប់វាស់វែងលទ្ធផលផ្នែកបរិស្ថាន។
៤. នៅមានកង្វះខាតនៃ**តម្រូវការផ្នែកច្បាប់** សម្រាប់របាយការណ៍ស្តីពីនិរន្តរភាព និងភាពបន្សុីគ្នាជាមួយក្របខ័ណ្ឌសំខាន់ៗ។
៥. **លទ្ធភាពទទួលបានធនធាន** និងគំនិតផ្តួចផ្តើមនៃ**កិច្ចសហការនៅមានកម្រិត** ក្នុងការអនុវត្តរបាយការណ៍ស្តីពីនិរន្តរភាពប្រកបដោយប្រសិទ្ធភាព។
៦. **ការកើនឡើងនូវតម្រូវការសម្រាប់តម្លាភាពទិន្នន័យ និងក្រមប្រតិបត្តិអ្នកផ្គត់ផ្គង់កាន់តែតឹងរ៉ឹង ជាមួយនឹងភាពមិនច្បាស់លាស់អំពីរបៀបដែលតុលាការនឹងបកស្រាយអំពីបទប្បញ្ញត្តិទាំងនេះ។**
៧. បង្កើនការយកចិត្តទុកដាក់លើ**យន្តការបណ្តឹងតវ៉ាមិនសុខចិត្ត** ដែលត្រូវតែជាផ្នែកមួយនៃកម្មវិធីលើកកម្ពស់ការចូលរួមរបស់និយោជិកប្រកបដោយប្រសិទ្ធភាព ដែលរួមបញ្ចូលវិធីលើកទឹកចិត្តដែលត្រឹមត្រូវ សូចនាករគន្លឹះស្តីពីសមិទ្ធផល និងអង្គភាពខាងក្រៅដូចជាសហជីពជាដើម។

## សេចក្តីសង្ខេបអនុសាសន៍

អនុសាសន៍ទាំងនេះត្រូវបានបង្កើតឡើងបន្ទាប់ពីការស្រាវជ្រាវឯកសារយ៉ាងទូលំទូលាយ ការពិគ្រោះជាមួយអ្នកជំនាញ ការទទួលបានគំនិតពីបុគ្គលក្នុងឧស្សាហកម្ម និងមតិកែលម្អពីកម្មវិធីសំខាន់ៗ ចំនួន ២ នៅក្នុងវិស័យ GFT៖ (១) កិច្ចពិភាក្សាវិស័យសាធារណៈ និងវិស័យឯកជន លើកទី ៥ ដែលរៀបចំដោយមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយទំនួលខុសត្រូវ និងគម្រោង GIZ FABRIC នៅថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ២០២៣ នៅសណ្ឋាគារ Hyatt Regency រាជធានីភ្នំពេញ ក្រោមចំណងជើងថា «ការរាយការណ៍ស្តីពីនិរន្តរភាព ឆ្នាំ ២០២៣៖ ដំណើរការស្វែងយល់ពីស្តង់ដារសកល» និង (២) សិក្ខាសាលា ដែលរៀបចំដោយគម្រោង GIZ FABRIC, CGTI, និង TAFTAC នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០២៤ នៅសាលប្រជុំរបស់ CGTI/TAFTAC រាជធានីភ្នំពេញ ដែលមានចំណងជើងថា «ការរាយការណ៍អំពី ដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវផ្អែកសិទ្ធិមនុស្ស និងបរិស្ថាន (HREDD) និងនិរន្តរភាពសម្រាប់អ្នកបញ្ជាទិញអន្តរជាតិ»។

ដោយក្តីគោរព យើងសូមផ្តល់នូវអនុសាសន៍ដូចខាងក្រោម៖

## សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖

១. **ផ្តល់ភាពជាអ្នកដឹកនាំ** និងការលើកទឹកចិត្តសម្រាប់ប្រព័ន្ធគ្រប់គ្រងដ៏រឹងមាំ ដោយផ្តោតលើ **សិទ្ធិមនុស្ស ធនធាន និងការគ្រប់គ្រងទិន្នន័យបរិស្ថាន**សម្រាប់អាជីវកម្មដែលផ្តោតលើការនាំចេញ។
២. **ដោះស្រាយគម្លាតនៃរបាយការណ៍ស្តីពីនិរន្តរភាព** តាមរយៈកម្មវិធីរបស់រដ្ឋាភិបាលដែលផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស។
៣. **ការផ្សាភ្ជាប់ច្បាប់ជាតិជាមួយស្តង់ដារអន្តរជាតិ** (ឧ. អនុសញ្ញា ILO) និងធានាឱ្យមានការអនុវត្តដោយស្មើភាព និងយុត្តិធម៌។
៤. **បង្កើនភាពជាដៃគូពាណិជ្ជកម្ម** ដើម្បីទទួលបានការការពារផ្នែកហិរញ្ញវត្ថុ កិច្ចសន្យា និងកេរ្តិ៍ឈ្មោះសម្រាប់ក្រុមហ៊ុនដែលចែករំលែកទិន្នន័យនិរន្តរភាពប្រកបដោយតម្លាភាព។

## សម្រាប់ក្រុមហ៊ុន GFT ក្នុងស្រុក៖

១. **បង្កើតរចនាសម្ព័ន្ធអភិបាលកិច្ចឆ្លងមុខងារ** ដើម្បីប្រមូល វិភាគ និងរាយការណ៍ទិន្នន័យ ESG និងនិរន្តរភាពនៅទូទាំងអាជីវកម្ម។
២. **ចូលរួមជាមួយអ្នកពាក់ព័ន្ធ** ដើម្បីស្វែងយល់ពីបញ្ហានិរន្តរភាព និងបង្កើតការពិគ្រោះយោបល់សម្រាប់ការកំណត់អត្តសញ្ញាណ កាត់បន្ថយ និងដោះស្រាយផលប៉ះពាល់បរិស្ថាន និងសិទ្ធិមនុស្ស។
៣. **បង្កើតវិធីសាស្ត្រ** ស្តីអំពីរបាយការស្តីពីនិរន្តរភាពដែលបន្ថែមគុណតម្លៃសម្រាប់អ្នកទិញ អតិថិជន វិនិយោគិន និងប្រតិបត្តិការអាជីវកម្ម និង**ដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងហានិភ័យសិទ្ធិមនុស្ស។**

## សម្រាប់ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិ៖

១. **ផ្តល់ការអភិវឌ្ឍន៍សមត្ថភាព**ផ្តោតលើសមត្ថភាពសំខាន់ៗសម្រាប់ការរាយការណ៍អំពីនិរន្តរភាព។
២. **សហការជាមួយវិស័យឯកជន** ជាពិសេសសមាគមនានា ដើម្បីណែនាំអ្នកផ្គត់ផ្គង់ និងម្ចាស់ម៉ាក អំពី HREDD ។
៣. **កោះប្រជុំជាមួយវិស័យឯកជន ដើម្បីកំណត់ឧបសគ្គ និងឱកាស** សម្រាប់ការសហការ ឬការវិនិយោគលើធនធានរួម។

## សម្រាប់អ្នកបញ្ជាទិញ៖

១. **ដឹកនាំដោយបង្ហាញឧទាហរណ៍** - ធានាឱ្យមានក្រុមការងារតំណាងនិរន្តរភាពនៅថ្នាក់ដឹកនាំ និងក្រុមប្រឹក្សា ដោយបញ្ជ្រាបនៅក្នុង ប្រតិបត្តិការរបស់អ្នក។
២. **ទទួលខុសត្រូវលើការអនុវត្តចំពោះការស្វែងរកប្រភពផ្គត់ផ្គង់** រួមបញ្ចូលការកំណត់តម្លៃសមរម្យដែលគិតគូពីតម្លៃអាជីវកម្ម រួមបញ្ចូល ការចំណាយ ហានិភ័យ ដែលទាក់ទងជាមួយការគ្រប់គ្រងនិងប្រមូលទិន្នន័យ និងរបាយការណ៍ ព្រមទាំងការកំណត់និងកាត់បន្ថយហានិភ័យ និងដំណោះស្រាយបញ្ហា និងរាយការណ៍អំពីផលប៉ះពាល់ដល់មនុស្សក្នុងប្រតិបត្តិការផ្គត់ផ្គង់។
៣. **បង្កើតទំនួលខុសត្រូវរួមគ្នា** ជាមួយដៃគូខ្សែចង្វាក់ផ្គត់ផ្គង់ដោយកំណត់សូចនាករគន្លឹះស្តីពីសមិទ្ធផលសមហេតុផល និងការលើកទឹកចិត្តល្អ។

## សម្រាប់សង្គមស៊ីវិល៖

១. **ចូលរួមក្នុងកិច្ចសន្ទនា**ក្នុងន័យស្ថាបនាជាមួយឧស្សាហកម្ម ដើម្បីលើកកម្ពស់របាយការណ៍ស្តីពីនិរន្តរភាព។
២. **ផ្តល់ការកសាងសមត្ថភាព**ជាពិសេសសម្រាប់សហជីព តំណាងកម្មករ និងយន្តការបណ្តឹងតវ៉ាមិនសុខចិត្ត ស្របតាម HREDD និងបរិបទក្នុងស្រុក។

## ដំណើរឆ្ពោះទៅមុខ៖ ការត្រៀមខ្លួនរបស់កម្ពុជាសំរាប់វិស័យ GFT នាពេលអនាគត

ការផ្លាស់ប្តូរ បញ្ញត្តិនាពេលថ្មីៗនេះ និងការកើនឡើងនៃចំនួនប្រទេសដែលកំពុង អនុម័តច្បាប់ស្តីពីផលប៉ះពាល់បរិស្ថាន សិទ្ធិមនុស្ស និងនិរន្តរភាព បង្ហាញឱ្យច្បាស់ថា ទិដ្ឋភាពខ្សែចង្វាក់ផលិតកកម្មសកល និងតួនាទីរបស់ពួកគេក្នុងការកាត់ផ្តាច់អ្នកប្រើប្រាស់ឲ្យនៅឆ្ងាយ ពីផលប៉ះពាល់បរិស្ថាន និងមនុស្ស នៃផលិតផលដែលពួកគេទិញ គឺមិនអាចទទួលយកបាន ទៀតនោះទេ នៅតាមបណ្តាប្រទេសនៅលោកខាងជើង។ ការធ្វើអាជីវកម្មនៅក្នុងទីផ្សារធំៗដូចជា អឺរ៉ុប សហរដ្ឋអាមេរិក កាណាដា កូរ៉េខាងត្បូង ជប៉ុន អូស្ត្រាលី ចក្រភពអង់គ្លេស និងចិន នឹងតម្រូវឱ្យក្រុមហ៊ុននានាទទួលស្គាល់ពីផលប៉ះពាល់អវិជ្ជមានរបស់ពួកគេ និងត្រួតពិនិត្យ និងដោះស្រាយបញ្ហាទាំងនេះជាលក្ខណៈប្រព័ន្ធ។

ផ្ទុយពីវិធីសាស្ត្រពីមុនដែលផ្តោតលើអនុលោមភាព បទប្បញ្ញត្តិថ្មីស្តីពីនិរន្តរភាព និងការត្រួតពិនិត្យភាពត្រឹមត្រូវ បញ្ជាក់ពីការកំណត់ហានិភ័យយ៉ាងសកម្ម ការប្រមូលទិន្នន័យដែលអាចជឿជាក់បាន និងសកម្មភាពកែតម្រូវ ជាជាងគ្រាន់តែបង្កើតគោលនយោបាយ និងការបណ្តុះបណ្តាល ។

នៅកម្ពុជា បញ្ហាធនធានមនុស្ស ដូចជាសិទ្ធិការងារ និងសុខុមាលភាពកម្មករ និងការខូចខាតបរិស្ថាន ដូចជាការបំពុល និងការថយចុះធនធាន ត្រូវបានគេទទួលស្គាល់ថាជាហានិភ័យផ្នែកហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុននៅក្នុងវិស័យ GFT របស់កម្ពុជា។ វាអាចប៉ះពាល់យ៉ាងខ្លាំងដល់ប្រាក់ចំណេញ កេរ្តិ៍ឈ្មោះ និងនិរន្តរភាពយូរអង្វែងរបស់ក្រុមហ៊ុន ដោយនាំទៅដល់ការផាកពិន័យ ការពន្យារផលិតកម្ម ការបាត់បង់កិច្ចសន្យា ឬការខូចខាតដល់កេរ្តិ៍ឈ្មោះរបស់ពួកគេ ប្រសិនបើមិនមានការគ្រប់គ្រងត្រឹមត្រូវ។

ការសិក្សាថ្មីមួយបានរកឃើញដោយសាលា CamED Business School **៧៤**% នៃបុគ្គលដែលបានស្ទង់មតិនៅក្នុងប្រទេសកម្ពុជាបានដឹងពីការរាយការណ៍អំពីនិរន្តរភាព ប៉ុន្តែតិចជាង **៣០**% ដែលត្រៀមខ្លួនក្នុងការធ្វើរបាយការណ៍ណាមួយអំពីផលប៉ះពាល់បរិស្ថាន ឬសង្គមនៃប្រតិបត្តិការអាជីវកម្មរបស់ពួកគេ។ ការសិក្សានេះបានសន្និដ្ឋានថា កង្វះនៃច្បាប់ជាតិដែលតម្រូវឱ្យមានការរាយការណ៍អំពីនិរន្តរភាព គឺជាកត្តារួមចំណែកយ៉ាងសំខាន់ដល់ប្រទេសកម្ពុជាដែលកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការបង្ហាញព័ត៌មានដែលមិនមែនអំពីហិរញ្ញវត្ថុនិងនិរន្តរភាព។  ការស្ទង់មតិក៏បានបង្ហាញផងដែរថាបុគ្គល **៦៨**% បានយល់ស្របថាព័ត៌មានដែលមិនបង្ហាញ អំពីហិរញ្ញវត្ថុ ក៏ដូចជាព័ត៌មានហិរញ្ញវត្ថុ ឬរបាយការណ៍និរន្តរភាព មានអត្ថប្រយោជន៍ដល់កេរ្តិ៍ឈ្មោះ និងម៉ាករបស់ពួកគេ។

ខណៈពេលដែលមិនមានក្របខ័ណ្ឌច្បាប់នៅក្នុងប្រទេសកម្ពុជាសម្រាប់ការរាយការណ៍អំពីនិរន្តរភាព កូតាដាក់បន្ថែមផ្នែកច្បាប់មិនមែនជាផ្លូវយុទ្ធសាស្ត្រតែមួយគត់ឆ្ពោះទៅមុខសម្រាប់ប្រទេសកម្ពុជា និងវិស័យ GFT នោះទេ។ នៅក្នុងប្រទេសជាច្រើន ក្រុមហ៊ុនដែលបានចុះបញ្ជី និងនិយោជកធំៗផ្សេងទៀតត្រូវបានតម្រូវឱ្យធ្វើរបាយការណ៍ស្តីពីនិរន្តរភាពមួយចំនួន របាយការណ៍ដែលស្របតាមស្តង់ដារអន្តរជាតិដូចជា GRI ឬ ISSB ឬស្តង់ដារដែលកំណត់ដោយប្រទេសរីផ្សាហ៊ុនដែលពួកគេចុះបញ្ជី។ តាមរយៈការលើកកម្ពស់ស្តង់ដារអន្តរជាតិ បណ្តាប្រទេសទាំងនេះបង្កភាពងាយស្រួលដល់វិនិយោគិន និងអតិថិជនអន្តរជាតិ ក្នុងការស្វែងយល់ពីកិច្ចខិតខំប្រឹងប្រែងផ្នែកនិរន្តរភាព និងសមិទ្ធិផលធុរកិច្ចនិរន្តរភាពដែលត្រូវបានយល់ដោយអ្នកវិនិយោគគិនខាងក្រៅនិងអ្នកបញ្ជារទិញ។

រដ្ឋាភិបាលក៏អាចផ្តល់នូវភាពជាអ្នកដឹកនាំ និងការប្តេជ្ញាចិត្តដ៏សំខាន់លើនិរន្តរភាព ក៏ដូចជាយន្តការសម្របសម្រួលការគាំទ្រ និងធនធាន ដើម្បីពន្លឿនអាជីវកម្ម ឧ. ការលើកទឹកចិត្តដល់ការផលិតប្រកបដោយនិរន្តរភាព និងការធ្វើទីផ្សារពីតម្លៃបន្ថែមរបស់ផលិតផលដែលមានទិន្នន័យនិរន្តរភាព; ការផ្តល់ឱកាសផ្តល់មូលនិធិ និងកម្មវិធីផ្តល់ជំនួយដោយផ្ទាល់ ឬតាមរយៈឥណទានកាបូន មូលបត្របំណុលបៃតង ឬវិធីសាស្ត្រផ្សេងទៀត; ការសម្របសម្រួលការបញ្ចូលគ្នានៃស្តង់ដារ និងតម្រូវការ; ការកោះប្រជុំភាគីពាក់ព័ន្ធដើម្បីបំភ្លឺបញ្ហាជាក់លាក់នៃបរិបទ និងធ្វើជាគំរូនៃការចូលរួមក្នុងន័យស្ថាបនារវាងអាជីវកម្ម និងភាគីពាក់ព័ន្ធដទៃទៀត; និងការកសាងសមត្ថភាពសម្រាប់ក្រុមការងារផ្នែកគ្រប់គ្រង និងសមាជិក នឹងធានាថាក្រុមហ៊ុននៅកម្ពុជាត្រៀមខ្លួនរួចរាល់ក្នុងការសហការជាមួយអ្នកបញ្ជារទិញ ដែលតម្រូវអោយមាន ទិន្នន័យ ឬរបាយការណ៍ប្រកបដោយនិរន្តរភាព។ ការផ្សារភ្ជាប់ ការចូលរួម និងការគាំទ្រពីវិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ក៏ជាកត្តាសំខាន់សម្រាប់ការត្រួសត្រាយផ្លូវដ៏ច្បាស់លាស់បំផុត សម្រាប់អាជីវកម្ម GFT របស់កម្ពុជា ក្នុងការរួមបញ្ចូលរបាយការណ៍ស្តីពីនិរន្តរភាពជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ពួកគេ។

# Executive Summary

This Sustainability Recommendations Paper (SRP) on **Sustainability Reporting in the Garment, Footwear and Travel Goods (GFT)** Sector aims to strengthen the foundations for environmental, social and governance **(ESG)** practices and data collection and management for reporting. This is increasingly important, as new HREDD legislation, mostly from Global North (buyer markets), is likely to set a backdrop for evolving sustainability reporting requirements in the future.

The EU is one of Cambodia's largest destination markets for GFT products, with an export value of **$2.9 billion** destined for European retail customers in 2024 under all **EBA** (Everything But Arms) categories (textiles, footwear, bicycles, foodstuffs, milled rice, and other agricultural products). Therefore, recent EU legislation on sustainability reporting and human rights due diligence and the attendant requirements will have a significant impact on the GFT sector and its ability to continue to provide products of the quality needed for EU markets.

While an estimated **80%** of top **50** listed companies in **Asia-Pacific** adopt the **Global Reporting Initiative (GRI)** framework, existing national laws and guidelines in Cambodia **do not include sustainability reporting, nor even environmental, social and governance reporting** apart from some requirements set out in the 2023 Environmental Code. This gap leaves a large burden on individual companies to build and procure the tools, systems and processes needed to fulfill buyer and other stakeholder requirements, resulting in confusion, increased costs, and potential loss of buyers in favor of producing countries with more advanced sustainability reporting in place.

Relevant studies agree that "Among a wide range of sustainability-related issues, climate change and human capital are the most prevalent issues in Asia and globally." Studies also show that investors look favorably on ESG reporting as a hallmark of transparency and accountability, meaning that countries with sustainability reporting will be able to more easily attract investment.

For Cambodia, we do not recommend creating new national sustainability reporting requirements from scratch, as this field is still evolving. Additional legislation could complicate compliance and increase costs for Cambodian export-oriented companies, potentially disadvantaging them in international markets. Instead, we suggest that the government develop incremental steps toward internationally accepted sustainability reporting standards. These steps would support local companies in meeting both domestic labor and environmental requirements and aligning with the data needs of international buyers. To be effective, these foundations should draw from established international legislation and guiding principles.

By maintaining a strong national approach to regulating environmental, labor, and other business impacts, Cambodia can project a cohesive vision of responsible business while allowing companies, especially those in export sectors, the flexibility to adapt to international reporting standards.

For instance, the Royal Government of Cambodia and the GFT industry could establish non-legislative support for GFT companies, helping them implement new HREDD standards. They could also create a common framework for sustainability reporting tailored to Cambodian GFT companies, referencing global frameworks like the UNGPs, OECD Guidelines, ILO Conventions, and environmental standards. This could serve as a practical guide for Tier 1 factories that will be mandated to adhere to HREDD Standards, and could be a support to the non-exporting, Tier 2 and Tier 3 factories to initiate sustainability reporting. We encourage the Royal Government to seize this opportunity.

The United Nations Guiding Principles on Business and Human Rights (UNGPs) and the OECD Due Diligence Guidance for Responsible Supply Chains in the Garment & Footwear Sector (OECD Guidelines) are well established and accepted and are the foundations on which much recent legislation on human rights and environmental due diligence (HREDD) is based.

This could be achieved by providing tools for data measurement, offering financial and technical support to help companies adopt sustainable practices, and improving management systems, especially for tracking environmental and social impacts. Progress in sustainability reporting will lead to better operations, enhanced environmental and social outcomes, and increased competitiveness for Cambodian businesses, particularly with EU clients who may pay a premium for reliable sustainability data. Government leadership will be crucial in aligning stakeholders to drive this transformation.

## Key Challenges

This paper highlights key challenges related to sustainability reporting in Cambodia's GFT sector:

1. **Low awareness of sustainability principles,** including data management and transparency.

2. **Limited data collection** and **management systems** within factories.

3. **Lack of accessible tools** for **measuring environmental** metrics.

4. **Gaps in national legal requirements** for sustainability reporting, **missing alignment** with key frameworks.

5. **Limited access to resources** and **collaborative initiatives** to implement sustainability cost-effectively.

6. Growing **demands for data transparency** and **stricter supplier codes of conduct,** with uncertainty around how courts will interpret these regulations.

7. **Increased emphasis** on **grievance mechanisms,** which must be part of effective worker engagement programs, supported by the right incentives, KPIs, and external entities like trade unions.

## Summary Recommendations

These recommendations have been developed following extensive desk research, expert consultations, industry input, and feedback from two key events in the GFT sector: (1) The fifth public-private dialogue hosted by the Responsible Business Hub and GIZ FABRIC on 2 November 2023 at the Hyatt Regency, Phnom Penh, titled "Sustainability Reporting in 2023: Navigating Global Standards," and (2) the workshop and closing event hosted by GIZ FABRIC, CGTI, and TAFTAC on 19 September 2024 at the CGTI/TAFTAC Auditorium, Phnom Penh, titled "Reporting on HREDD and Sustainability Requirements for International Buyers.

**We respectfully recommend:**

### For the Government of Cambodia

1. **Provide leadership** and **incentives** for **strong management systems,** focusing on human rights, resources, and environmental data management for export-oriented businesses.

2. **Address sustainability reporting gaps** through **government programs** offering financial and technical support.

3. **Align national laws** with **international standards** (e.g., ILO Conventions) and ensure fair, equal enforcement.

4. **Leverage trade partnerships** to secure financial, contractual, and reputational protections and mutual obligations from client companies for Cambodian companies sharing transparent sustainability data.

### For Local GFT Companies

1. **Establish a cross-functional governance structure** to collect, analyze, and report ESG and sustainability data across the business.

2. **Engage with stakeholders** to understand sustainability issues and **create consultations** for identifying, mitigating, and addressing environmental and human rights impacts.

3. **Develop a sustainability reporting approach** that adds value for buyers, investors, and business operations, addressing climate change and human rights risks and facilitates your ability to negotiate for better pricing and terms.

### For Development Partners and International Organizations

1. **Offer capacity-building opportunities** focused on key competencies for sustainability reporting.

2. **Collaborate with the private sector,** especially associations, to guide suppliers and brands on HREDD.

3. **Convene the private sector** to identify barriers and opportunities for **collaboration or investment in shared resources.**

### For Buyers

1. **Lead by example**—ensure sustainability representation at the leadership and board levels, **embedding it throughout your operations.**

2. **Practice responsible sourcing,** including fair pricing that considers the cost of doing business and the costs and risks associated with data collection, management and reporting, and identifying, mitigating, remedying and reporting on risks to people in supplier operations.

3. **Create shared responsibility** with supply chain partners by setting reasonable KPIs and good incentives and providing financial and technical support to suppliers.

### For Civil Society and Trade Unions

1. **Engage in constructive dialogue** with industry to promote sustainability reporting.

2. **Provide capacity building,** especially for unions, worker representatives, and grievance mechanisms, tailored to HREDD and national contexts.

## The Way Forward: Future Proofing Cambodia's GFT Sector

Recent legislative changes and the growing number of countries enacting laws on environmental impact, human rights, and sustainability make it clear that the nature of global value chains, and their role in distancing consumers from the environmental and human impacts of the products they purchase is no longer acceptable in much of the Global North. Doing business in major markets like Europe, the US, Canada, South Korea, Japan, Australia, the UK, and China will soon require companies to recognize their negative impacts and systematically monitor and address them over time.

Unlike the compliance-driven approaches of the past, new regulations on sustainability and due diligence emphasize proactive risk identification, reliable data collection, and corrective actions, rather than simply creating policies and conducting training.

In Cambodia, human capital issues, such as labor rights and worker wellbeing, and environmental damage, like pollution and resource depletion, are recognized as financially material risks for companies in Cambodia's GFT sector. They can significantly impact a company's profitability, reputation, and long-term sustainability by leading to fines, production delays, loss of contracts, or damage to their reputation if not effective managed.

A recent study by CamED Business School found that **74%** of people surveyed in Cambodia were aware of sustainability reporting but fewer than **30%** were prepared to do any reporting on environmental or social impacts of their business operations. The study concludes that the **lack of a national law** requiring sustainability reporting was a significant contributing factor to Cambodia being in such an early stage of non-financial and sustainability disclosure. The survey also revealed that **68%** of people agreed that non-financial as well as financial information or sustainability reporting is beneficial, for the disclosing party's reputation and brand.

**While no legal framework exists** in Cambodia for sustainability reporting, additional legislation is not the only strategic path forward for Cambodia and the GFT sector. In many countries, listed companies and other large employers are required to do some kind of sustainability reporting, either in line with international standards like GRI or ISSB, or bespoke standards set by the country or stock exchange they are listed on. By promoting international standards, countries make it easier for their businesses' sustainability efforts and achievements to be understood by outside investors and buyers.

**National governments** can also provide **important leadership** and **commitment on sustainability,** as well as **coordinate support** and **resources to help businesses** get up to speed, e.g. encouraging production with sustainability and marketing the additional value of products with sustainability data; providing funding opportunities and grant programs either directly or through carbon credit, green bonds or other methods; facilitating the convergence of standards and requirements; convening stakeholders to illuminate context specific issues and to model constructive engagement between business and other stakeholders; and capacity building for management teams and members would go a long way in ensuring that Cambodian companies are prepared to engage with their buyers who require sustainability data or reports. The alignment, involvement and support of the private sector, civil society, and development partners is also crucial for facilitating the clearest path for Cambodian GFT businesses to include sustainability reporting as part of their annual reports.

Deutsche Gesellschaft für
Internationale Zusammenarbeit (GIZ) GmbH

GIZ Office Phnom Penh
Oval Office Tower, 10F Building No. 1 Street 360, Boeung Keng Kang 1
Phnom Penh, Cambodia
T +855 23 860 110
E giz-kambodscha@giz.de
I www.giz.de/cambodia